I-ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៤

អនុក្រឹត្យលេខ ៦២ អ.ន.ក្រ

ស្តីពីការបង្កើតប្រតិភូបណ្តោះអាសន្ន នៃ

កម្មវិធីផលិតស្បៀងជាលក្ខណៈគ្រួសារ « ផ.ស.គ »

* * *

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័នព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី០១ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើតរាជរដ្ឋាភិបាលកម្ពុជា

-តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានអភិវឌ្ឍន៍ជនបទ

ស ម្រេ ច

មាត្រា ១ : បង្កើតប្រតិភូមួយមានឈ្មោះថា « ប្រតិភូបណ្តោះអាសន្ន ផ.ស.គ » ដែលមានសមាសភាពដូចតទៅ ៖

១-ឯកឧត្តមយឹម នៃលី អនុរដ្ឋលេខាធិការអភិវឌ្ឍន៍ជនបទ ប្រធាន

២-ឯកឧត្តម ឈា សុខ អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ សមាជិក

៣-លោកស្រីរស់ ស៊ីខណ្ឌា តំណាងរដ្ឋលេខាធិការកិច្ចការនារី សមាជិក

៤-លោក ថន ឈុំ តំណាងក្រសួងអប់រំយុវជន និង កីឡា សមាជិក

៥-លោកវេជ្ជបណ្ឌិត គឹមអាន តំណាងក្រសួងសុខាភិបាល សមាជិក

៦-លោក ទី ច័ន្ទផល អគ្គនាយកអភិវឌ្ឍន៍ជនបទ សមាជិក

៧-លោក ទ្រី ឆេង ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ សហគមន៍ លេខាធិការ

មាត្រា ២ : ប្រតិភូបណ្ដោះអាសន្ន << ផ.ស.គ >> មានភារៈកិច្ចរៀបចំបែបបទផ្ទេរទាំងស្រុងនូវកម្មវិធីផលិតស្បៀង លក្ខណៈគ្រួសារ<<ផ.ស.គ>>ដែលកន្លងមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ រដ្ឋលេខាធិការដ្ឋានកិច្ចការនារី ក្រសួងអប់រំយុវជន និង កីឡា ក្រសួងសុខាភិបាល អោយទៅរដ្ឋលេខាធិការដ្ឋានអភិវឌ្ឍន៍ជនបទគ្រប់គ្រងនិងទទួលខុសត្រូវ ។ ដោះស្រាយការងារចំពោះមុខនិងបន្តសហប្រតិបត្តិការ ជាមួយអង្គការ (UNICEF) ដែលជាម្ចាស់ជំនួយកម្មវិធី ផ.ស.គ

មាត្រា ៣ : សមាជិកប្រតិភូបណ្ដោះអាសន្ន<<ផ.ស.គ>>ត្រូវចូលរួម ប្រជុំនិងធ្វើការងារតាមការអញ្ជើញ និង ណែនាំរបស់ប្រធាន ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានកិច្ចការនារី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋានអនុរដ្ឋលេខាធិការគ្រប់ រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្ដម លោក លោកស្រី ដែលមាននាមចែង ក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ហត្ថលេខាតទៅ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

រាជធានីភ្នំពេញ ថ្ងៃ ទី ១៣ ខែ តុលា ឆ្នាំ១៩៩៤

អនុក្រឹត្យលេខ ៦៣ អ.នក្រ

ស្តីពីការប្រគល់ភារកិច្ច និង សិទ្ធិក្នុងការលក់

និង ធ្វើការនាំចេញផលិតផលកៅស៊ូជូនក្រសួង

កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុវរ្ម័នព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញក្រឹត្យលេខ ១២ ក្រ ចុះថ្ងៃទី ១០ កុម្ភៈ ឆ្នាំ ១៩៩០ ប្រកាសអោយប្រើច្បាប់ ស្តីពីការកែប្រែការចាត់តាំងតួនាទី និង ភារកិច្ចរបស់អគ្គនាយកដ្ឋានចំការកៅស៊ូ

-បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃអគ្គនាយកដ្ឋានចំការកៅស៊ូ

-បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១៩ សីហា ឆ្នាំ១៩៩៣ ស្តីពីអគ្គនាយកដ្ឋានចំការកៅស៊ូត្រូវស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-យោងតាមស្មារតីនៃអង្គ ប្រជុំការងារក្រោម ព្រះរាជាធិបតីភាពនិងអធិបតីភាពសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ និង សម្តេចនាយករដ្ឋមន្ត្រីទី ២ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៤ នៅទីរួមខេត្តកំពង់ចាម

សំរេច

មាត្រា ១ : ប្រគល់ភារកិច្ច និង សិទ្ធិជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (អគ្គនាយកដ្ឋានចំការកៅស៊ូ) ក្នុងការចាត់ចែងលក់ សំរាប់បំរើផលិតកម្មឧស្សាហកម្ម-សិប្បកម្មក្នុងស្រុក និង ធ្វើការនាំចេញនូវផលិតផលកៅស៊ូ

គ្រប់ប្រភេទ លើកលែងតែជ័រកៅស៊ូបង្គក ដែលត្រូវសុំសេចក្ដីសំរេចឯកភាពពីរាជរដ្ឋាភិបាល ព្រមទាំងធ្វើការនាំចូល នូវសំភារៈបរិក្ខារគ្រឿងបន្លាស់ និង មធ្យោបាយបំរើការងារផ្សេង ៗ បំរើអោយអាជីវកម្ម ផលិត - កម្មកៅស៊ូ និង ការដាំដុះថ្មី ។

មាត្រា ២ : ក្រោយពីបានបំពេញកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ តាមច្បាប់កំណត់ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ (អគ្គនាយកដ្ឋានចំការកៅស៊ូ) ត្រូវគ្រប់គ្រងចំណូលទាំងអស់ដែលបានមកពីការលក់ ផលិតផលកៅស៊ូគ្រប់ប្រភេទនេះសំរាប់ដោះស្រាយចំណាយក្នុងដំណើរការអាជីវកម្ម ផលិតកម្មកៅស៊ូ តាំងពីបៀវត្សរហូតដល់ទុនសំរាប់នាំចូលសំភារៈ បរិក្ខារគ្រឿងបន្លាស់ និង មធ្យោបាយ បំរើការងារផ្សេង ៗ តាមតម្រូវការចាំបាច់ ។ ឯទុនវិនិយោគ សំរាប់ការដាំដុះការថែទាំកូនកៅស៊ូ ពុំទាន់អោយផល និង ការសាងសង់ ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវលើកគំរោងច្បាស់លាស់ ស្នើសុំរាជរដ្ឋាភិបាល តាមគោល ការណ៍ ជាធុរៈមាន ឬ អាចដោះស្រាយយកចំណូលមួយចំណែកបានមក ពីការលក់ផលិតផលកៅស៊ូ នេះយកមកប្រើប្រាស់ក្នុងករណី មានលទ្ធភាព ផ្ទុយទៅវិញក្នុងករណីប្រធានស័ក្តណាមួយសភាពការណ៍មិនអនុគ្រោះ នាំអោយបាត់តុល្យភាពរវាងចំណូល និង ចំណាយ ក្រសួងកសិកម្មរុក្ខា ប្រមាញ់ និង នេសាទ ត្រូវធ្វើរបាយការណ៍ លំអិតពីសភាពការណ៍ និង មូលហេតុជាក់ស្តែង រាយការណ៍ជូនរាជ រដ្ឋាភិបាល សុំជួយបំពេញបន្ថែមថវិកាមួយចំណែក ដើម្បីយកទៅដោះស្រាយការចាំបាច់មួយចំនួនក្នុងដំណើរការអាជីវកម្មផលិតកម្មកៅស៊ូដូចជាបៀវត្សជាដើម

មាត្រា ៣ : ក្នុងដំណើរការអនុវត្តន៍អាជីវកម្ម-ផលិតកម្ម ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ (អគ្គនាយកដ្ឋានចំការកៅស៊ូ) មានសិទ្ធិប្រើប្រាស់រូបិយប័ណ្ណដែលបានមកពីការលក់នាំចេញផលិតផល កៅស៊ូគ្រប់ប្រភេទនេះចំនួន ៣០% ដើម្បីនាំចូលអ្វីដែលជាតំរូវការក្នុងអាជីវកម្ម ផលិតកម្មកៅស៊ូ ។

ឯកសារនិយប័ណ្ណនៅសល់ពីនេះត្រូវលក់ជូនរដ្ឋ តាមគោលការណ៍ច្បាប់ជាធរមាន ។

មាត្រា ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ និង អនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តតាមភារកិច្ចរៀងៗ ខ្លួននូវអនុក្រឹត្យ នេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ១៩៩៤

អនុក្រឹត្យលេខ ១១៥ អ.នក្រ

ស្តីពីការជូន រមេជាយស្លាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែមេសា ឆ្នាំ១៩៩៤

សំរេច

មាត្រា ១ : តែងតាំងព្រះអង្គម្ចាស់ក្សត្រីយ៍ សម្តេចព្រះរាម ពុប្ផាទេវី ជាអ្នកទទួលខុសត្រូវផ្ទាល់ចំពោះក្រុមរបាំព្រះរាជទ្រព្យ (ក្រុមរបាំព្រះបរមរាជវាំង) ដោយធ្វើការហាត់ហ្វឹកហ្វឺនរៀនសូត្រ នៅក្នុងព្រះបរមរាជវាំង ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួល បន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈរដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ក្រសួងរដ្ឋលេខាធិការអនុរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន និងព្រះអង្គម្ចាស់ក្សត្រីយ៍ សម្តេចព្រះរាមអនុវត្តតាមអនុក្រឹត្យនេះចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

២-សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ១៩៩៥

សេចក្តីសំរេចលេខ ១២០ សសរ

ស្តីពីការបង្កើតគណៈកម្មការអន្តរជំនាញឯកទេស

អំពីបញ្ហាអណិកជនវៀតណាម

* * *

រដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីពីអន្តោប្រវេសន៍ ដែលប្រកាសអោយប្រើដោយព្រះ រាជក្រម ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤

-តាមសំណូមពរការងារចាំបាច់

សំរេច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មការមួយ ឈ្មោះគណៈកម្មការ អ្នកជំនាញ ឯកទេស អំពីបញ្ហាអាណិកជនវៀតណាម ដែលមានសមាសភាពដូចខាង ក្រោម ៖

១-តំណាងក្រសួងមហាផ្ទៃ ជាប្រធាន

២-តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៣-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៤-តំណាងក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ជាសមាជិក

ប្រការ ២ : គណៈកម្មការអ្នកជំនាញឯកទេសអំពីអាណិកជនវៀតណាម មានភារកិច្ច ពន្យល់ភាគីវៀតណាមអំពីការបកស្រាយនូវច្បាប់ ស្តីពីអន្តោប្រវេសន៍ ដែលបកាសអោយប្រើដោយព្រះរាជ ក្រមចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ១៩៩៤

ប្រការ ៣ : សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំ និង អនុវត្តការងារតាមការ អញ្ជើញ របស់ប្រធានគណៈកម្មការ ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហ ប្រតិបត្តិការ អន្តរជាតិ រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃ ក្រសួងនិងស្ថាប័ន ដែលមានការពាក់ព័ន្ធ និង

អស់លោកដែលជាតំណាង ក្រសួងស្ថាប័នដែលមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណឫទ្ធិ ហ៊ុន សែន

រាជធានីភ្នំពេញ ថ្ងៃ ទី ១២ ខែ តុលា ឆ្នាំ១៩៩៤

សេចក្ដីសំរេចលេខ ១២១ សសរ

ស្ដីពីការបន្ថែមសមាសភាពគណៈកម្មការចំរុះដោះស្រាយ

បញ្ហាជនអនាថាក្នុងរាជធានីភ្នំពេញ

* * *

រដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែល ប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

-យោងសេចក្ដីសំរេចលេខ ៣៣ សសរ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើតគណៈកម្មការចំរុះដោះ ស្រាយបញ្ហាជនអនាថា ក្នុងរាជធានីភ្នំពេញ ។

-យោងតាមការងារចាំបាច់ចំពោះមុខ